**KINGDOM OF CAMBODIA**
**NATION - RELIGION - H.M.THE KING**

Mr Nguon Soeur, President of the Khmer Citizen Party
**Respectfully submitted to:**
His Majesty the King Samdech Norodom Sihanouk

**Subject:** Request for His Majesty the King to abdicate.

As the above mentioned subject, I, Nguon Soeur President of the Khmer Citizen Party would like to submit this request for the following reasons :

As I observe: The current Royal Government is unable to perform its duties and accomplish its programs because the two parties in power often face with crisis and disputes created by the FUNCINPEC, and especially because of the disunification within the FUNCINPEC itself, between H.E. Toan Chay and Samdech Norodom Ranariddh which finally caused the National Assembly unable to proceed as planned.

With regard to his responsibilities, His Majesty the King did not fulfill his duties which are his obligation, because His Majesty never stay permanently in Cambodia due to his political ailment and some of his physical illnesses.

Parallel with this, His Majesty the King is willing to abdicate, and recently His Majesty has declared that His Majesty is an expatriate as his brother, Prince Norodom Sereivuth.

Furthermore, His Majesty the King wanted to sue others, such as movie stars etc..., and His Majesty had never thought of his people but in the contrary His Majesty is always ready to create problems.

As His Majesty the King has already known that the current Royal Government, on behalf of Cambodian people has spent seven million U.S dollars of the national budget each year to fund the Royal Palace where His Majesty is the King who serves as a shade to Cambodian people. His Majesty the King did not perform these duties instead.

For these reasons, I propose that His Majesty should choose:

1. Either to abdicate and stay for ever in China, enabling Cambodian people to use these seven million dollars each year to build our country and to help indigent people.
2. Or His Majesty the King should return to Cambodia to resolve the above mentioned crisis.

Finally, I would like to wish His Majesty the King good health and longevity.

Respectfully submitted in Phnom Penh on June 30, 1997.

Your obedience,

ទីស្នាក់ការកណ្តាលៈ ផ្ទះលេខ ៨៣ ផ្លូវលេខ ១៥០ សង្កាត់ផ្សារដេប៉ូ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters: House # 83 Street 150 Sangkat Phsa Depot 2 Khan Tuol Kork.
Phnom Penh. Kingdom of Cambodia.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទូលព្រះបង្គំ ខួន សឿរ ប្រធានគណបក្សពលរដ្ឋខ្មែរ

សូមក្រាបបង្គំទូលថ្វាយ

ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

សូមទ្រង់ជ្រាប ។

**កម្មវត្ថុ** : ស្នើសុំព្រះករុណាសូមឱ្យព្រះអង្គទ្រង់ដាក់រាជ្យ ។

យោងកម្មវត្ថុខាងលើ ទូលព្រះបង្គំ **ខួន សឿរ** ប្រធានគណបក្សពលរដ្ឋខ្មែរ សូមព្រះរាជានុញ្ញាតក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ សូមទ្រង់ព្រះមេត្តាជ្រាបនូវមូលហេតុដូចតទៅនេះ ៖

ទូលព្រះបង្គំសង្កេតឃើញថា ៖

រាជរដ្ឋាភិបាលបច្ចុប្បន្ននេះពុំអាចបំពេញករណីយកិច្ច និងកម្មវិធីរបស់ខ្លួនបាន ព្រោះគណបក្សកាន់អំណាចទាំងពីរចេះតែមានវិបត្តិឈ្លោះប្រកែកគ្នា ដែលបង្កឡើងដោយសារគណបក្សហ្វ៊ុនស៊ិនប៉ិច ជាពិសេសគឺបញ្ហាដែលគណបក្សហ្វ៊ុនស៊ិនប៉ិចបែកបាក់គ្នារវាង ឯ.ឧ ទន់ ចាយ និងសម្តេច ន. រណឫទ្ធិ ចុងក្រោយនេះដែលធ្វើឱ្យសភាជាតិពុំអាចដំណើរការទៅបានតាមការគ្រោងទុក ។

រីឯព្រះមហាក្សត្រព្រះអង្គមិនបានបំពេញព្រះរាជកិច្ចនិងការងារ ដែលទ្រង់ត្រូវបំពេញ ព្រោះព្រះអង្គពុំដែលគង់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសខ្មែរឡើយ ដោយសារជំងឺនយោបាយព្រមទាំងព្រះរោគខ្លះផង ។

ទន្ទឹមនេះព្រះអង្គក៏មានបំណងដាក់រាជ្យ ហើយថ្មីៗនេះព្រះអង្គក៏មានព្រះរាជបន្ទូលថា៖ ព្រះអង្គជាជននិរទេសដូចព្រះរាជអនុជរបស់ព្រះអង្គដែរ គឺទ្រង់នរោត្តម សិរីវុឌ្ឍ ។ ក្រៅពីនេះព្រះអង្គចង់ប្តឹងអ្នកនេះអ្នកនោះដូចជាត្នកុនជាដើម ព្រះអង្គពុំបានគិតដល់កូនចៅព្រះអង្គម្តងណាសោះ ផ្ទុយទៅវិញព្រះអង្គចង់តែបង្កើតបញ្ហា ។

ហេតុនេះដូចទ្រង់ជ្រាបហើយថាព្រះរាជរដ្ឋាភិបាលបច្ចុប្បន្ន ក្នុងនាមប្រជារាស្ត្រខ្មែរបានចំណាយថវិកាជាតិចំនួនប្រាំពីរលានដុល្លារអាមេរិកកាំងក្នុងមួយឆ្នាំ សម្រាប់ផ្គត់ផ្គង់ដល់ព្រះបរមរាជវាំង ដែលមានព្រះអង្គជាព្រះរាជាដើម្បីគ្រប់គ្រងប្រជារាស្ត្រជាម្ចប់ដ៏ត្រជាក់ តែផ្ទុយទៅវិញព្រះអង្គបែរមិនបានបំពេញកត្តព្វកិច្ចនេះឡើយ ។

ដោយមូលហេតុនេះទូលព្រះបង្គំ សូមស្នើឱ្យព្រះអង្គទ្រង់ជ្រើសរើស ៖

ទី១ : ទ្រង់ដាក់រាជ្យ ហើយគង់នៅប្រទេសចិនជារៀងរហូតទៅ ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរយកប្រាក់ប្រាំពីរលានដុល្លារក្នុងមួយឆ្នាំនេះ យកទៅកសាងប្រទេសជាតិ និងជួយដល់ប្រជារាស្ត្រក្រីក្រទៅវិញ ។

ទី២ : ឬមួយព្រះអង្គយាងមកប្រទេសយើងវិញ ដើម្បីដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរ ដូចទូលព្រះបង្គំទូលថ្វាយខាងលើនេះ ។

ជាទីបញ្ចប់សូមព្រះករុណាព្រះអង្គទទួលនូវព្រះសុខភាពល្អ ព្រះជន្មាយុយឺនយូរ ។

ក្រាបបង្គំទូលថ្វាយ នៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៧

ទូលព្រះបង្គំ

ខួន-សឿរ

ទីស្នាក់ការកណ្តាលៈ ផ្ទះលេខ ៨៣ ផ្លូវលេខ ១៥០ សង្កាត់ផ្សារដេប៉ូ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters: House # 83 Street 150 Sangkat Phsa Depot 2 Khan Tuol Kork.
Phnom Penh. Kingdom of Cambodia.